ជំនួយស្មារតី

វ៉ុល១ លេខទី១ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩

# ការស្វែងយល់អំពីប្រព័ន្ធអនុគ្រោះពន្ធ "អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ"

ចាន់ ផល្លីកា*

កាលពីប៉ុន្មានសប្តាហ៍មុន នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ សហភាពអឺរ៉ុប បានចាប់ផ្តើមនីតិវិធីជាផ្លូវការនៃការដកគម្រោង "អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ" ហៅកាត់ថា EBA (Everything but Arms) ជាបណ្តោះអាសន្នពីព្រះរាជាណាចក្រកម្ពុជា។ នៅក្រោម ប្រព័ន្ធ EBA ផលិតផលដែលនាំចេញពីប្រទេសកម្ពុជាទៅកាន់ទីផ្សារអឺរ៉ុប ត្រូវបានលើកលែងពីកាតព្វកិច្ចពន្ធគយ ហេតុនេះហើយសហភាពអឺរ៉ុបបានក្លាយជាទីផ្សារធំបំផុតសម្រាប់ការនាំចេញរបស់កម្ពុជា។ ដោយសារតែប្រព័ន្ធEBA នេះ បានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេស គម្រោងក្នុងការដកកម្ពុជាចេញពីប្រទេសដែលទទួលប្រយោជន៍ពីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនេះ បាននាំឱ្យមានការជជែកពិភាក្សាដ៏ស៊ីជម្រៅអំពីកង្វល់ និងផលប៉ះពាល់អវិជ្ជមានជាច្រើនដែលអាចកើតមានលើប្រទេសកម្ពុជា។ ការដក EBA ជាបណ្តោះអាសន្ន បានក្លាយជាប្រធានបទដែលប្រជាជនកម្ពុជាកំពុងតែចាប់អារម្មណ៍ ហើយលើកយកមកពិភាក្សា ជាពិសេសចំពោះប្រជាជនដែលពាក់ព័ន្ធ ហើយអាចទទួលផលប៉ះពាល់ដោយផ្ទាល់ ពីការដកជាបណ្តោះអាសន្ននេះ។ លើសពីនេះទៀត អត្ថបទទាក់ទងនឹងផលប៉ះពាល់នៃការដក EBA ពីកម្ពុជា ជាច្រើន ត្រូវបានបោះពុម្ពផ្សាយ និងចែកចាយយ៉ាងទូលំទូលាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។ យ៉ាងណាមិញ ប្រជាជនមួយចំនួននៅពុំទាន់មានការយល់ដឹងច្បាស់អំពី អ្វីទៅជា EBA ហើយវាមានដំណើរការបែបណានៅឡើយ។ ដូច្នេះហើយ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបអំពី EBA ។

## ប្រវត្តិរបស់ប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP)

នៅឆ្នាំ១៩៦៨ សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ ហៅកាត់ថា UNCTAD បានផ្តួចផ្តើមផែនការពាណិជ្ជកម្មដ៏សំខាន់មួយ ដែលត្រូវបានស្គាល់ដោយសាធារណជនថាជា ប្រព័ន្ធអនុគ្រោះពន្ធទូទៅ ហៅកាត់ថា GSP (General System of Preferences) ដែលផ្តល់ប្រយោជន៍ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការផ្តល់ជំនួយពាណិជ្ជកម្មពីប្រទេសដែលមានការរីកចម្រើនខ្ពស់ផ្នែកឧស្សាហកម្ម។ GSP មានគោលបំណងដើម្បីបង្កើនការនាំចេញរបស់ប្រទេសកំពុងអភិវឌ្ឍន៍ លើកកម្ពស់ឧស្សាហូបនីយកម្ម និងពន្លឿនកំណើនសេដ្ឋកិច្ចរបស់ប្រទេសទាំងនោះ។ ចំពោះ GSP របស់សហភាពអឺរ៉ុបវិញ វាមានការបែងចែកជាបីប្រព័ន្ធដូចជា GSP ស្តង់ដា, GSP លើកទឹកចិត្ត និង EBA។ GSP ស្តង់ដា ជាគម្រោងដែលផ្តល់ឲ្យបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប ឬប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ហើយពុំធ្លាប់ទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មណាមួយរបស់សហភាពអឺរ៉ុប ឲ្យទទួលបានការកាត់បន្ថយពន្ធនាំចូល ចំនួន ៦៦ ភាគរយ លើទំនិញទៅកាន់ទីផ្សាររបស់សហភាពអឺរ៉ុប។ ដូចគ្នានឹង GSP ស្តង់ដាដែរ GSP លើកទឹកចិត្ត ដែលត្រូវបានគេស្គាល់ថាជា GSP(+) ផ្តល់ការលើកលែងពន្ធចំនួន ៦៦ ភាគរយ ទៅឲ្យប្រទេសដែលនឹងទទួលបានផលពីប្រព័ន្ធនេះ ប៉ុន្តែប្រទេសនោះត្រូវធ្វើសច្ចាប័ន និងធ្វើការអនុវត្តនូវអនុសញ្ញាអន្តរជាតិសំខាន់ៗចំនួន២៧ ដែលត្រូវបានចែងនៅក្នុងបទប្បញ្ញត្តិ

*ចាន់ ផល្លីកា ជាអ្នកសម្របសម្រួលកម្មវិធីគោលនយោបាយ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

របស់ GSP ក្នុងនោះរួមមានសិទ្ធិមនុស្ស ការការពារបរិស្ថាន និងអភិបាលកិច្ចល្អ។ ចំណែកឯប្រព័ន្ធមួយទៀតនោះគឺ EBA ដែលជាប្រធានបទក្ដៅគគុក កំពុងត្រូវបានលើកយកមកពិភាក្សានៅក្នុងប្រទេសកម្ពុជា ពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់កម្ពុជានាពេលបច្ចុប្បន្ន។ ចំពោះ EBA នេះ ដូចដែលបានបញ្ជាក់តាមរយៈឈ្មោះហើយថា វាជាប្រព័ន្ធផ្ដល់ឲ្យដល់បណ្ដាប្រទេសអភិវឌ្ឍន៍តិចតួច ដើម្បីនាំចេញផលិតផលរបស់ខ្លួនទាំងអស់ លើកលែងតែអាវុធ ទៅកាន់ទីផ្សារអឺរ៉ុប ដោយលើកលែងកាតព្វកិច្ចពន្ធគយ។

## ប្រព័ន្ធអនុគ្រោះពន្ធ EBA និងគោលការណ៍ទូទៅ

EBA ត្រូវបានអនុម័តនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០១ និងត្រូវបានចូលជាធរមាននៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០០១ ដែលដាក់បញ្ចូលប្រទេសអភិវឌ្ឍន៍តិចតួចចំនួន៤៨ រួមទាំងកម្ពុជាផងដែរ ទៅក្នុងបញ្ជីប្រព័ន្ធអនុគ្រោះពន្ធនេះ។ ប្រព័ន្ធនេះ មានគោលបំណងសម្រួលដល់ប្រទេសអភិវឌ្ឍន៍តិចតួច ដើម្បីលើកកម្ពស់ពាណិជ្ជកម្ម និងពង្រឹងសេដ្ឋកិច្ចរបស់ពួកគេតាមរយៈការលើកលែងកាតព្វកិច្ចពន្ធគយនេះ។ យោងតាមបទប្បញ្ញត្តិលេខ ៩៧៨/២០១២ របស់សភា និងក្រុមប្រឹក្សាអឺរ៉ុប ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ទាក់ទងនឹងកិច្ចព្រមព្រៀងពិសេស សម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច ដូចមានចែងនៅក្នុងជំពូកទី៤ មាត្រា១៧ ថាប្រទេសស្ថិតនៅក្នុងបញ្ជីទទួលស្គាល់ជាប្រទេសអភិវឌ្ឍន៍តិចតួច ដោយអង្គការសហប្រជាជាតិ មានសិទ្ធិក្លាយខ្លួនទៅជាប្រទេសដែលអាចទទួលបានផលប្រយោជន៍ពី EBA (សហភាពអឺរ៉ុបឆ្នាំ២០១២ ទំព័រ ១០)។ នៅពេលដែលប្រទេសណាមួយបញ្ចប់ឋានៈរបស់ខ្លួន ពីប្រទេសអភិវឌ្ឍន៍តិចតួច ប្រទេសនោះនឹងត្រូវបាត់បង់សិទ្ធិទទួលបានផលប្រយោជន៍ពីប្រព័ន្ធនេះ ដោយហេតុថាប្រទេសទាំងនោះមានសមត្ថភាព និងសកម្មភាពឧស្សាហកម្មខ្ពស់។ ជាគោលការណ៍ មិនថា GSP ស្ដង់ដា, GSP លើកទឹកចិត្ត ឬ EBA ទេ ការវិវត្តរបស់ប្រទេសដែលនឹងទទួលបានប្រព័ន្ធនេះ ត្រូវឆ្លងកាត់ដំណើរការដូចខាងក្រោម។ ដំណាក់កាលដំបូង គឺការប្រកាសខ្លួនជាប្រទេសដែលមានសិទ្ធិទទួលយក GSP និងការចូលទីផ្សារសហភាពអឺរ៉ុប។ ដំណាក់កាលទីពីរ គឺបង្កើនផលិតផលនាំចេញរបស់ខ្លួន រួមទាំងការបង្កើនប្រភេទមុខទំនិញនាំចេញទៅកាន់ទីផ្សារអឺរ៉ុប។ ដំណាក់កាលទីបី គឺបង្កើនការនាំចូលផលិតផលពីសហភាពអឺរ៉ុបមកក្នុងស្រុក ស្របពេលដែលប្រភេទមុខទំនិញរបស់ខ្លួនមួយចំនួនដែលនាំចេញទៅទីផ្សារអឺរ៉ុបបានបាត់បង់ អត្ថិភាពនៃការលើកលែងពន្ធនាំចេញ។ ចុងក្រោយ ប្រទេសជាសិទ្ធិវ័ន នឹងបញ្ចប់អត្ថិភាពនោះ និងលែងទទួលបានការលើកលែងពន្ធពីសហភាពអឺរ៉ុប។ យ៉ាងណាមិញ ការព្យួរជាប្រព័ន្ធ EBA ជាបណ្ដោះអាសន្ន ក៏អាចធ្វើឡើងមុនពេលដែលអត្ថិភាពរបស់ប្រទេសនោះបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីសេដ្ឋកិច្ចខ្លួនមានការរីកចម្រើន ដូចបានចែងនៅក្នុង ជំពូក៥ មាត្រា១៩ ទាក់ទងនឹងបទប្បញ្ញត្តិទូទៅ សម្រាប់កិច្ចព្រមព្រៀងទាំងអស់សំដៅលើការដកប្រព័ន្ធជាបណ្ដោះអាសន្ន។ ដូច្នេះហើយ ហេតុផលណាមួយ ដែលបណ្ដាលឲ្យមានការព្យួរប្រព័ន្ធនេះ ត្រូវតែគោរពតាមមាត្រា១៩(វាក្យខណ្ឌទី១)។

## តើការដក EBA ត្រូវដំណើរការយ៉ាងដូចម្ដេច?

នីតិវិធីនៃការដក EBA ត្រូវគោរពតាមមាត្រា១៩ វាក្យខណ្ឌ៤ និងវាក្យខណ្ឌទាំងឡាយ ដែលស្ថិតនៅក្នុងមាត្រាដដែល។ ដើម្បីដកលក្ខខណ្ឌពិសេសពីប្រទេសទទួលផលណាមួយ ជាដំបូង គណៈកម្មការត្រូវអនុម័តយកវិធានការអនុវត្តដើម្បីចាប់ផ្ដើមនីតិវិធីព្យួរប្រព័ន្ធបណ្ដោះអាសន្នពីប្រទេសណាមួយ ហើយត្រូវជូនដំណឹងដល់សភា និងក្រុមប្រឹក្សារបស់អឺរ៉ុបរាល់វិធានការអនុវត្តទាំងនោះ។ បន្ទាប់មក ការជូនដំណឹងនេះត្រូវដាក់ផ្សាយនៅក្នុងរដ្ឋកិច្ចផ្លូវការ នៃសហភាពអឺរ៉ុបទាក់ទងនឹងការចាប់ផ្ដើមនៃនីតិវិធីព្យួរជាបណ្ដោះអាសន្ន រួមជាមួយនឹង

ហេតុផលគ្រប់គ្រាន់ ដែលធ្វើឲ្យមានការចាប់ផ្តើមនីតិវិធីនេះ និងផ្តល់ព័ត៌មានអំពីបេសកកម្ម រួមមានការត្រួតពិនិត្យ និងការវាយតម្លៃលើស្ថានភាពរបស់ប្រទេស ដែលស្ថិតនៅក្នុងនិតិវិធីព្យួរប្រព័ន្ធ EBA ជាបណ្តោះអាសន្ន ដោយមានរយៈពេលប្រាំមួយខែ។ បីខែបន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតអស់រយៈពេលដូចបានចែងខាងលើ គណៈកម្មការត្រូវផ្តល់របាយការណ៍ចុងក្រោយ នៃការស៊ើបអង្កេតរបស់ខ្លួនដល់ប្រទេសសាមី ដើម្បីអនុវត្តសិទ្ធិឆ្លើយតបទៅនឹងរបាយការណ៍របស់គណៈកម្មការអឺរ៉ុបជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេលមួយខែ។ ក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីគណៈកម្មការសហភាពអឺរ៉ុបធ្វើការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពរបស់ប្រទេសដែលមានអត្ថិភាពទទួលយកប្រព័ន្ធនោះហើយ គណៈកម្មការសហភាពអឺរ៉ុប ត្រូវធ្វើការសម្រេចចិត្តថា តើត្រូវបញ្ចប់នីតិវិធីព្យួរប្រព័ន្ធ ឬធ្វើការព្យួរប្រព័ន្ធពីប្រទេសនោះ។ ប្រសិនបើការរកឃើញរបស់គណៈកម្មការនេះ មិនមានភាពត្រឹមត្រូវទេនោះ គេចាំបាច់ត្រូវមានការអនុម័តវិធានការអនុវត្ត ដែលអនុលោមតាមមាត្រា៣៩ (វាក្យខណ្ឌ២) នៃបទប្បញ្ញត្តិខាងលើ។ ប៉ុន្តែបើសិនជាគណៈកម្មការរកឃើញថា ការសន្និដ្ឋាននេះ មានភាពត្រឹមត្រូវស្របទៅនឹងហេតុផលដូចមានចែងក្នុងវាក្យខណ្ឌ១នៃមាត្រា១៩ ការព្យួរប្រព័ន្ធ EBA ជាបណ្តោះអាសន្ននឹងត្រូវបានអនុវត្ត នៅក្នុងពេលប្រាំមួយខែបន្ទាប់ពីការអនុម័តសេចក្តីសម្រេចនេះ។

| ដំណាក់កាល | ដំណាក់កាលទីមួយ | ដំណាក់កាលទីពីរ | ដំណាក់កាលទីបី | | | ដំណាក់កាលទីបួន |
|---|---|---|---|---|---|---|
| **ថិរវេលា** | - | ៦ខែ | ៦ខែ | | | ៦ខែ |
| | | | បីខែ | មួយខែ | ពីរខែ | |
| **សកម្មភាព** | គណៈកម្មការ<br>សហភាពអឺរ៉ុប<br>អនុម័តវិធានការអនុវត្ត<br><br>ជូនដំណឹងដល់សភា<br>និងក្រុមប្រឹក្សាអឺរ៉ុប<br><br>ផ្សព្វផ្សាយសេចក្តីជូន<br>ដំណឹងនៅក្នុងរដ្ឋកិច្ច<br>សហភាពអឺរ៉ុប | ត្រួតពិនិត្យ និង<br>វាយតម្លៃប្រទេស<br>ទទួលផល | គណៈកម្មការ<br>សហភាពអឺរ៉ុបផ្តល់<br>របាយការណ៍លើ<br>ការរកឃើញ និង<br>សេចក្តីសន្និដ្ឋាន<br>របស់ខ្លួន | ប្រទេសទទួល<br>ផលអនុវត្ត<br>សិទ្ធិឆ្លើយតប | សេចក្តី<br>សម្រេច៖<br><br>(១)បញ្ចប់<br>នីតិវិធីព្យួរ<br>ប្រព័ន្ធ ឬ<br><br>(២)ធ្វើការ<br>ព្យួរប្រព័ន្ធ | ការអនុម័ត<br>សេចក្តីសម្រេច<br><br>សេចក្តីសម្រេចនឹង<br>ត្រូវបានអនុវត្ត ក្នុង<br>រយៈពេល០៦ខែ<br>ក្រោយការអនុម័ត |

***Source:*** *Regulation (EU) No. 978/2012 of the European Parliament and of the Council of October 25, 2012, Chapter V: Temporary withdrawal provisions common to all arrangements*

## ឯកសារយោង


Council of the European Union. (2018). *Council Conclusion on Cambodia.* Brussels.

European Commission. (2013). *Revised EU Trade Scheme to Help Developing Countries Applied on 01 January 2014.* Brussels: European Commission.

European Union. (2012). Regulations (EU) No. 978/2012 of the European Parliament and of the Council of 25 october 2012. 10.

UNCTAD. (2016). *The Least Developed Countries Report 2016: The Path to Graduation and Beyong-Making the Most of the Process.* UNCTAD.



Cambodia Development Center

Cambodia Development Center (@cdcenter_kh)

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Cambodia Development Center

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | ☎ (+855) 16 616 951